www.khmerpostusa.com

សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អ

# KhmerPost USA

Lowell - Lynn - Revere - MA * Providence - Cranston - RI

Free Copies

Vol. 13. Issue #295
June 26Th, 2020
Office: 978-677-7163
Direct: 978-656-8141
Email:Khmerpostusa@gmail.com

**ព័ត៌មានសំខាន់ៗខាងក្នុង...**

ឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត អះអាង.

សូមអានទៅទំព័រទី ០៣



គយជ្រៃធំចាប់បន្លែមានជាតិគីមីដឹកពីវៀតណាម...

សូមអានទៅទំព័រទី ០៨



ម្ចាស់ភោជនីយដ្ឋានជួយគ្រួសាររងគ្រោះ..

សូមអានទៅទំព័រទី ១២



វិចារណកថា

# កឹម សុខា អាចត្រឡប់ចូលឆាកនយោបាយសាជាថ្មីបានឬទេ?

ដោយ ពិន សំខុន

ទំនងជាមិនបានទេ! បើយោងទៅតាមការរក្សាតុលាការ ហ៊ុន សែន សម្រាប់ត្រួតត្រាសេរីភាពរបស់ កឹម សុខា។ បច្ចុប្បន្ននៅតែជាប្រធាននៃអតីតគណបក្សសង្គ្រោះជាតិនៅឡើយ "ក៏ប៉ុន្តែបើយោងទៅតាមចំណុចកណ្ដាលនយោបាយ នៅកម្ពុជាវិញ បែរជាគេឃើញថា ភ្នែកពិភពលោកបានផ្ដោតទៅលើ កឹម សុខា ដែលទំនងជាច្រកដំណោះស្រាយកម្ពុជាតែមួយគត់ ដែលគេសង្ឃឹមថា នឹងដំណើរការប្រកបដោយសន្តិភាពទៅរួច បើលោក សុខា លេងល្បែងនយោបាយយ៉ាងឆ្លាតវៃជាមួយលោក ហ៊ុន សែន បន្តទៅទៀតបាន។ **តទៅទំព័រទី ០៩**





# Summer Life in New England During Covid-19 Pandemic

By Soben Pin

After being confined for nearly 4 months since the pandemic outbreaks in March, people are trying to find their "new normal" life understanding that thousands of lives are still lost everyday across the United States. Here in New England, Massachusetts, where I live, there are over 100,000 people infected with covid-19 and that nearly 10,000 thousands people died. I myself have suffered a great deal during the pandemic by having lost my mother to cancer and unable to travel to be with her because of the travel restrictions. Store closures caused our newspaper circulation to drop in the last three months; but we managed to print two issues in April, with reduced quantity, one issue in May and one in June. In July, as New England reopening is going to into phase two, we are resuming two issues per month.

In the last two weeks, we spent time going outdoors for the first time after quarantining ourselves for three months.

**Read page10**

Pleas



មេធាវី លុយ ហាស្កែល LAW OFFICE OF LOUIS S. HASKELL

សេវាកម្មជាទីគាប់ចិត្តចាប់តាំងពីឆ្នាំ 1987

គ្រោះថ្នាក់ចរាចររថយន្តធុនតូច, រថយន្តធុនធំ និងម៉ូតូ • អន្តោប្រវេសន៍
ធ្វើពន្ធ • ការក្ស័យធន • គ្រោះថ្នាក់រអិលដួល • ឆ្កែខាំ
ដំណោះស្រាយ និងការពារបញ្ហាពន្ធដា

សូមអរគុណចំពោះការបន្តទុកចិត្តរបស់លោកអ្នកមកលើការិយាល័យមេធាវីយើងខ្ញុំ ក្នុងការដោះស្រាយបញ្ហាផ្នែកច្បាប់ និងពន្ធដារជូនលោកអ្នក ។ យើងខ្ញុំរំពឹងថា និងបន្តបម្រើលោកអ្នកយ៉ាងល្អនាពេលអនាគត។

បុគ្គលិកយើងខ្ញុំនិយាយភាសាខ្មែរ

*Excellent Service Since 1987*

Auto, Truck and Motorcycle Accidents
Immigration • Tax • Bankruptcy
Slip & Fall • Dog Bite
Tax Resolution & Defense

*Thank you for your continued confidence*
*In our office to handle your legal and tax matters.*
*We look forward to serving you well into the future.*

LAW OFFICE OF LOUIS S. HASKELL * 16 PINE STREET * LOWELL, MA * (978) 459-8359

16 Pine Street • Lowell, MA • 978-459-8359 • www.attorneyhaskell.com

# សូមបំពេញជំរឿន ឆ្នាំ-2020 សម្រាប់ សហគមន៍របស់ យើង។



ជំរឿនឆ្នាំ 2020 គឺដើម្បីធ្វើការរាប់ចំនួនប្រជាពលរដ្ឋគ្រប់ៗរូប ដែលរស់នៅក្នុងសហរដ្ឋអាមេរិក។ សូមជួយបំពេញជំរឿននៅថ្ងៃនេះ ដើម្បីទទួលបានសេចក្ដីជូនដំណឹងអំពីជំនួយរាប់ពាន់លានដុល្លារអាមេរិក នឹងជួយដល់គ្លីនិកសុខភាព សេវាសង្គ្រោះបន្ទាន់ និងវិស័យអប់រំជារៀងរាល់ឆ្នាំ សម្រាប់រយៈពេលដប់ឆ្នាំខាងមុខទៀតនេះ។

**សូមបំពេញជំរឿនតាមអនឡាញ ឬ តាមប្រអប់សំបុត្រ។ ដើម្បីស្វែងយល់ពីរបៀបបំពេញសូមមើលគេហទំព័រនេះ 2020CENSUS.GOV/km**

**2020CENSUS.GOV/km**

ឧបត្ថម្ភដោយ ក្រសួងជំរឿនប្រជាជនសហរដ្ឋអាមេរិក (U.S. Census Bureau)

**Shape your future START HERE >**

United States® Census 2020

# ឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត អះអាងថា រថយន្តយោធាទាំង ២៩០គ្រឿង ត្រូវបានបញ្ជាទិញពីចិនតាំងពីមុនពេលផ្ទុះកូវីដ១៩

(ភ្នំពេញ)៖ រថយន្តយោធាទំនើបៗធុនធំទាំង២៩០គ្រឿង ត្រូវបានបញ្ជាទិញពីប្រទេសចិន តាំងពីមុនពេលផ្ទុះជំងឺកូវីដ១៩ម្ល៉េះ។ នេះបើតាមឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក។

ការអះអាងរបស់លោកឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត បានធ្វើឡើងបន្ទាប់ពីមានអ្នកវិភាគមួយចំនួនយល់ច្រឡំថា កម្ពុជាបានប្រើប្រាស់ថវិកាដើម្បីទិញរថយន្តយោធាខណៈពេលដែលប្រទេសកំពុងត្រូវបានវាយប្រហារដោយជំងឺកូវីដ១៩។ ដោយការយល់ច្រឡំនោះ ក្រុមអ្នកវិភាគថែមទាំងបានលើកឡើងទៀតថា ខណៈជំងឺកូវីដ១៩ កំពុងរាតត្បាតនោះ កម្ពុជាមិនគួរចំណាយថវិកាទៅទិញរថយន្តយោធាទាំងនេះសោះឡើយ ហើយនេះគឺជាការប្រើប្រាស់ថវិកាខុសគោលដៅ។

ថ្លែងនៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០ ក្នុងឱកាសអញ្ជើញជាអធិបតី ចែកជូនរថយន្តយោធាទាំងនេះ ដល់បណ្តាស្ថាប័នអង្គភាពនៃកងយោធពលខេមរភូមិន្ទ និងអគ្គស្នងការដ្ឋាននគរបាលជាតិ, បានបញ្ជាក់យ៉ាងដូច្នេះថា៖ "កុំគិតថា កងទ័ពកងនគរបាលជាតិ កងរាជអាវុធហត្ថ គ្មានខួរក្បាលពិចារណាដឹងពីកាលៈទេសៈ ពេលណាចាំបាច់ ពេលណាមិនចាំបាច់ចំណាយថវិកាលើអ្វី។ ខ្ញុំសូមបញ្ជាក់យើងបានធ្វើការជាមួយសប្បុរជនបញ្ជាទិញឱ្យរថយន្តយោធា" តាំងពីមុនពាក់កណ្តាលឆ្នាំ២០១៩ តាំងពីមុនកូវីដ-ផ្ទុះ។គេកក់លុយហើយ ទើបក្រុមហ៊ុនចាប់ផ្តើមធ្វើឡាន តាំងពីមុនពាក់កណ្តាលឆ្នាំ២០១៩"។



លោកបន្តថា "ឡានតាមពិតត្រូវយកមកប្រគល់នៅដើមឆ្នាំ២០២០ ខួង់ខែ២ ខែ៣នេះ តែវាចំពេលកូវីដផ្ទុះនៅចិន រោងចក្រគេពន្យាក្នុងការដឹកជញ្ជូន។ អញ្ចឹងដូចគ្នាការផលិតរថយន្ត ២៩០គ្រឿង មិនមែនផលិត១ថ្ងៃទេ ហើយគេក៏មិនផលិត បើបង់លុយឱ្យគេមិនគ្រប់។ បើសិនជាតម្រូវការរថយន្តយោធាចំពេលកូវីដផ្ទុះ យើងក៏មិនបញ្ជាទិញដែរ។ តម្រូវការកម្ចាត់កូវីដ វាធ្ងន់ជាងរថយន្ត ប៉ុន្តែរថយន្តនេះបានបញ្ជាទិញតាំងពីមុនកូវីដផ្ទុះ។ យើងបានកក់លុយគេហើយ គឺត្រូវតែយកដូចយើងកក់លុយកាត់ខោអាវដែរ។ បើយើងមិនយករថយន្តមកពេលនេះ តើចាំដល់ពេលណា"។

បើតាមលោកឧត្តមសេនីយ៍ឯក, ការទិញរថយន្តយោធាពីចិនទាំងនេះ នឹងជួយដល់ការងារបម្រើប្រទេសជាតិ និងប្រើប្រជាពលរដ្ឋបានកាន់តែល្អប្រសើរថែមទៀត។ បន្ថែមលើនេះ លោកបានណែនាំដល់អ្នកវិភាគទាំងឡាយឱ្យមានគំនិតជាតិនិយម និងយកការពិតមកនិយាយផងដែរ។





លោកថ្លែងទៀតថា អំឡុងពេលកូវីដនេះ កងកម្លាំងយោធា និងកងកម្លាំងសមត្ថកិច្ចមិនបានបំផ្លាញថវិកាជាតិឡើយ ផ្ទុយទៅវិញបែរជាបានបរិច្ចាគថវិកា ពេលមាតុភូមិត្រូវការពេលចាំបាច់ទៀតផង។ ជាក់ស្តែងកងកម្លាំងយោធា និងកងកម្លាំងសមត្ថកិច្ច ថែមទាំងបានធ្វើការឥតឈប់ឈរ ដោយមិនគិតពេលវេលាមានការរាតត្បាតដោយជំងឺឆ្លង តាមរយៈការជួយសម្រួលដល់ការដឹកប្រជាពលរដ្ឋ និងការត្រួតពិនិត្យអ្នកដំណើរឆ្លងដែនជាដើម។





មណ្ឌលពិនិត្យសុខភាពលីន
Lynn Primary Care Center
លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.
Sokharith Mey, M.D.
ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី
Now Accepting New Patients
អាស័យដ្ឋាន
280 Union Street, Unit 402 • Lynn, MA 01901 • (781) 780-7755
ទទួលយកម៉ាសហ៊ែល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

ជំងឺទូទៅ
Family Medicine
សុខភាពផ្លូវចិត្ត
Behavioral Health
We Accept MassHealth, Medicare and Other Health Insurances
Our Staff Speaks Khmer

# មណ្ឌលពិនិត្យសុខភាពឡូវែល

## Lowell Primary Care Center

លោកវេជ្ជបណ្ឌិត មី សុខារិទ្ធ, **M.D.**

**Sokharith Mey, M.D.**

លោក ឆាន់ ទូច , **C.N.P.**

**Chhan Touch, C.N.P.**





ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី

**Now Accepting New Patients**

ជំងឺទូទៅ

***Family Medicine*** &

សុខភាពផ្លូវចិត្ត

***Behavioral Health***

អាស័យដ្ឋាន

**1075 Westford Street, Unit 204 • Lowell, MA 01851 • (978) 455-7992**

ទទួលយកម៉ាសហែល, មេឌីឃែរ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

We Accept MassHealth, Medicare and Other Health Insurances
Our Staff Speaks Khmer • Plenty of Free Parking

# សមត្ថកិច្ចចាប់បន្លែ៦មុខ ដែលផ្ទុកកាកសំណល់ថ្នាំសម្លាប់សត្វល្អិត នាំចូលពីវៀតណាមតាមច្រកជ្រៃធំដុតកម្ទេចចោល

កណ្ដាលៈ សមត្ថកិច្ចច្រកទ្វារអន្តរជាតិជ្រៃធំ នៅព្រឹកថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០នេះ បានធ្វើការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពបន្លែ ផ្លែឈើគ្រប់ប្រភេទ ដែលអាជីវករខ្មែរនាំពីប្រទេសវៀតណាមចូលមកប្រទេសកម្ពុជា តាមច្រកទ្វារអន្តរជាតិជ្រៃធំ ដែលស្ថិតក្នុងភូមិជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល ដោយបានរកឃើញបន្លែចំនួន៦មុខ មានផ្ទុកកាកសំណល់ថ្នាំសម្លាប់សត្វល្អិត។





ប្រតិបត្តិការនេះដឹកនាំដោយលោក មួង ដារ៉ា ប្រធានការិយាល័យគយ និងរដ្ឋាករច្រក-ទ្វារអន្តរជាតិជ្រៃធំ, លោក អ៊ូ ម៉ានរិន ប្រធានសាខាការពារអ្នកប្រើប្រាស់កិច្ចការប្រកួតប្រជែងបង្ក្រាបការក្លែងបន្លំ (ក.ប.ប) សហការជាមួយ លោក សែ ជុនទ្រី ប្រធានស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិជ្រៃធំខេត្តកណ្ដាល ដើម្បីលើកកម្ពស់ការយកចិត្តទុកដាក់ចំពោះសុខភាពរបស់ប្រជាពលរដ្ឋ។

ក្នុងកិច្ចសហប្រតិបត្តិការណ៍នេះ ក.ប.ប បានយករថយន្តបំពាក់ដោយឧបករណ៍វិភាគទៅដល់ទីតាំងត្រួតពិនិត្យនៃការិយាល័យគយ និងរដ្ឋាករជ្រៃធំតែម្ដង ហើយបានធ្វើការវិភាគលើបន្លែចំនួន២២មុខ ដែលរួមមានៈ ស្ពៃបូកគោ, ត្រសក់, ស្ពៃក្ដោប, ត្រប់វែង, ប៉េងប៉ោះ, ផ្កាខាត់ណា, ពោតបារាំង, ផ្កាស្ពៃ, ក្រូចឆ្មារ, ឃ្លោក, ម្រះ, ម្ទេស, ត្រប់ស្រួយ, ល្ពៅ, ននោង, សណ្ដែកបារាំង, ក្រូចឆ្មារ (តែជ្រក់), ស្លឹកខ្ទឹម, ម្ទេសប្លោក, ប៉េង ប៉ោះខៀវ, ផ្កាគូឆាយ និងផ្កាខ្ទៀហៀង ជាដើម។

ក្នុងការត្រួតពិនិត្យនោះ សមត្ថកិច្ចជំនាញបានរកឃើញបន្លែចំនួន០៦មុខ រួមមានៈ ស្ពៃបូកគោ, ផ្កាខាត់ណា, ពោតបារាំង, ក្រូចឆ្មារតូច(សម្រាប់ធ្វើតែជ្រក់), ផ្លែល្ពៅ និងផ្កាគូឆាយ មានផ្ទុកកាកសំណល់ថ្នាំសម្លាប់សត្វល្អិត គ្មានសុវត្ថិភាពសម្រាប់ការប្រើប្រាស់ និងមិនអនុញ្ញាតឱ្យនាំចូលជាបណ្ដោះអាសន្ន។ ក្រៅពីនេះពុំឃើញមានជាតិគីមីពុល ឬខូចគុណភាពដែលនាំឱ្យប៉ះពាល់ដល់សុខភាពឡើយ ពោលគឺគុណភាពល្អ និងមានសុវត្ថិភាពសម្រាប់បរិភោគ។

លោក អ៊ូ ម៉ានរិន ប្រធានសាខា ក.ប.ប ខេត្តកណ្ដាលបានឱ្យដឹងថា ការចុះពិនិត្យនេះ លោកបានឱ្យក្រុមការងារឆែកយកបន្លែតាមប្រភេទនីមួយៗទៅច្រកថង់ផ្លាស្ទិកដែលគ្មានមេរោគ ដោយមានកត់ចំណាំលេខកូដតាមរថយន្ត និងឈ្មោះម្ចាស់ទំនិញ ដើម្បីយកទៅពិនិត្យធ្វើតេស្តគុណភាពលើបន្លែទាំងនេះ។



លោក មួង ដារ៉ា ប្រធានការិយាល័យគយ និងរដ្ឋាករច្រកទ្វារអន្តរជាតិជ្រៃធំ បានឱ្យដឹងដែរថា ក្រោយពីទទួលបានលទ្ធផលមុខទំនិញចំនួន៦មុខ ដែលមន្ត្រី ក.ប.ប ខេត្តកណ្ដាលរកឃើញមានផ្ទុកកាកសំណល់ថ្នាំសម្លាប់សត្វល្អិតទាំងនេះ លោកនឹងផ្អាកជាបណ្ដោះអាសន្នមិនឱ្យម្ចាស់ទំនិញនាំចូលមកកម្ពុជាទៀតទេ។ ចំពោះមុខទំនិញ និងបន្លែផ្សេងៗ លោកនឹងសហការជាមួយមន្ត្រី ក.ប.ប ដើម្បីពិនិត្យតាមដានបន្តទៀត ហើយប្រសិនបើរកឃើញបន្លែ នៅតែមានផ្ទុកកាកសំណល់ថ្នាំសម្លាប់សត្វល្អិត (សារធាតុ-គីមី) លោកនឹងបញ្ឈប់ឱ្យមានការនាំចូលតែម្ដង។





លោក មួង ដារ៉ា ក៏បានអំពាវនាវដល់ក្រុមអាជីវករខ្មែរ ដែលរកជំនួញបន្លែនាំពីប្រទេសវៀតណាមចូលមកកម្ពុជា គួរប្រុងប្រយ័ត្នដោយពិនិត្យទំនិញ និងដាក់លក្ខខណ្ឌជាមួយវៀតណាមឱ្យបានច្បាស់លាស់ មុននឹងនាំយកចូលមកកម្ពុជា។ បើសិនជាពួកគាត់នៅតែធ្វេសប្រហែសហើយនាំបន្លែដែលមានផ្ទុកកាកសំណល់ថ្នាំសម្លាប់សត្វល្អិត ដូចលើកនេះទៀតនោះ គាត់នឹងប្រឈមការខាតបង់លុយកាក់ដើមទុន ជាពិសេសប្រជាពលរដ្ឋកម្ពុជាដូចគ្នា ដែលទិញបន្លែរបស់ក្រុមអាជីវករនាំយកទៅលក់ឱ្យពួកគាត់ហូបនោះ គឺដូចកំពុងបំផ្លាញសុខភាពខ្មែរគ្នាឯងអញ្ចឹងដែរ។

លុះព្រឹកថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ កម្លាំងសមត្ថកិច្ចដែលដឹកនាំដោយលោក មួង ដារ៉ា ប្រធានការិយាល័យគយ និងរដ្ឋាករច្រកទ្វារអន្តរជាតិជ្រៃធំ, លោកវរសេនីយ៍ទោ វង្ស ចាន់ នាយនគរបាលប៉ុស្តិ៍ច្រកទ្វារអន្តរជាតិជ្រៃធំ និងលោក សែ ជុនទ្រី ប្រធានស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិជ្រៃធំបានបន្តចុះពិនិត្យគុណភាពបន្លែគ្រប់ប្រភេទ ដែលនាំពីប្រទេសវៀតណាមម្ដងទៀត ។ ក្នុងកិច្ចប្រតិបត្តិការណ៍ឆែកឆេរនោះសមត្ថកិច្ចក៏បានរកឃើញបន្លែចំនួន៥មុខរួមមានៈ ទី១-ផ្លែល្ពៅ ចំនួន៣៥៣០គីឡូក្រាម ទី២-ពោតបារាំងចំនួន៣៨០គីឡូក្រាម ទី៣-ក្រូចឆ្មាតែជ្រក់ ចំនួន១៨០០គីឡូក្រាម ទី៤-ស្លឹកដើមគូឆាយ ចំនួន១២០គីឡូក្រាម ទី៥-ស្ពៃបូកគោ ចំនួន១២០គីឡូក្រាម សរុប-ចំនួន៥៩១០គីឡូក្រាម បន្លែទាំង៥មុខនេះ គឺសមត្ថកិច្ចបានឆែរកាលពីថ្ងៃទី១២ ខែមិថុនា ឃើញមានសារធាតុកាកសំណល់ថ្នាំសំលាប់សត្វល្អិត(មានសារធាតុគីមី)ហើយបានហាមមិនអោយអាជីវករខ្មែរដឹកពីប្រទេសវៀតណាមមកប្រទេសកម្ពុជាទៀតទេ ពីព្រោះបន្លែទាំងនេះធ្វើអោយប៉ះពាល់សុខភាពរបស់ប្រជាពលរដ្ឋ តែអាជីវករខ្មែរនៅតែដឹកចូលទៀត ទើបសមត្ថកិច្ចចាប់យកទៅដុតកម្ទេចចោលតែម្ដងទៀត ។

លោក មួង ដារ៉ា បានបញ្ជាក់ទៀតថា ការអនុវត្តចាប់បន្លែនេះ កម្លាំងមិនត្រឹមតែចាប់ដកហូតបន្លែយកទៅដុតចោលប៉ុណ្ណោះទេ គឺថែមទាំងបានហៅម្ចាស់ធ្វើកិច្ចសន្យាបញ្ឈប់ការនាំចូលនូវបន្លែប្រភេទហាមឃាត់នេះ។ ប៉ុន្តែប្រសិនបើថ្ងៃ ក្រោយនៅតែនាំបន្លែប្រភេទនេះមកកម្ពុជាទៀត លោកនឹងបញ្ឈប់ឱ្យមានការរកស៊ីនាំបន្លែចូលមកកម្ពុជាតែម្ដង។

ដោយ FresNews

# ទឹកឃ្មុំមានប្រយោជន៍ចំពោះសម្រស់ច្រើនទឹកស្មានមិនដល់



ទឹកឃ្មុំគឺជាផលិតផលពីធម្មជាតិដែលមិនត្រឹមតែមានសារប្រយោជន៍ជាច្រើនចំពោះសុខភាពប៉ុណ្ណោះទេ តែក៏ល្អសម្រាប់សម្រស់នោះដែរ។ វាផ្ទុកនូវសមាសធាតុល្អៗដែលប្រឆាំងអុកស៊ីតកម្ម ហើយវាក៏ជាឱសថទិព្វដែលគួរមានក្នុងផ្ទះសម្រាប់ព្យាបាលជំងឺមួយចំនួនផងដែរ។ ចង់ដឹងថា ការប្រើប្រាស់ទឹកឃ្មុំល្អសម្រាប់សម្រស់យ៉ាងណានោះ សូមមើលដូចខាងក្រោមៈ

ញ៉ាំទឹកឃ្មុំមួយស្លាបព្រាជារៀងរាល់ថ្ងៃធ្វើឱ្យស្បែកស្រស់ថ្លា ទន់ និងភ្លឺរលោង។

លាយទឹកជាមួយទឹកឃ្មុំរួចយកមកលាបលើផ្ទៃមុខតិចៗអាចជួយជម្រះភាពកខ្វក់ និងធ្វើឱ្យផ្ទៃមុខមានសំណើម និងពណិស៊ីជម្ពូ។

-យកទឹកឃ្មុំលាបផ្ទាល់លើផ្ទៃមុខត្រង់កន្លែងមានមុនទុករយៈពេល១០ទៅ១៥នាទី រួចលាងជម្រះនឹងទឹកត្រជាក់។ ធ្វើបែបនេះអាចជួយឱ្យបញ្ហាមុនក្រហម និងរមាស់ អន់ថយបាន។

ទឹកឃ្មុំជួយបំបាត់ស្លាកស្នាមបានមួយកម្រិតផងដែរ ដោយអ្នកអាចលាបវាដោយផ្ទាល់ត្រង់កន្លែងស្លាកស្នាមក្រមៅនៅលើកែងដៃ ឬជង្គង់។

អ្នកអាចបករោមស្បែកជាមួយនឹងក្រមួនទឹកឃ្មុំ ដោយយកទឹកឃ្មុំលាយនឹងស្ករត្នោតរួចថែមទឹកក្រូចឆ្មារចូលគ្នារួចដាក់កម្តៅក្នុង Microwave ទុកឱ្យត្រជាក់បន្តិច ដូចនេះអ្នកអាចបករោមស្បែកបាន ដែលធ្វើឱ្យស្បែករលោង និងមានសំណើម។

ទឹកឃ្មុំអាចបំបាត់ស្នាមមុតឡាមកោរពុកមាត់បានដោយលាបវាលើស្បែកទុកពី១០ទៅ១៥នាទីរួចលាងជម្រះនឹងទឹកក្តៅឧណ្ហៗ។

-លាយទឹកឃ្មុំ និងទឹកប៉ោមចូលគ្នា រួចលាបលើក្រចកនិងស្បែកគល់ក្រចកជួយឱ្យក្រចករឹង ម៉្យាងទៀតអ្នកអាចលាយទឹកឃ្មុំ និងទឹក សម្រាប់ជាថ្នាំសម្លាប់មេរោគ។

អ្នកអាចបំបាត់ស្នាមក្រមៅនៅក្បែររង្វង់ភ្នែកដោយលាបទឹកឃ្មុំដោយផ្ទាល់ រួចទុកចោល២០នាទីជារៀងរាល់ថ្ងៃ វាអាចជួយឱ្យស្បែកភ្នែកទន់ភ្លឺរលោង។

ជួយឱ្យសក់លោកអ្នកភ្លឺរលោងបែបធម្មជាតិដោយគ្រាន់តែយកទឹកឃ្មុំលាយជាមួយទឹកក្រូចឆ្មារមកលាបលើសក់។

-អ្វីដែលពិសេសមួយទៀត គឺការញ៉ាំទឹកឃ្មុំអាចជួយប្រឆាំងភាពជ្រីវជ្រួញ និងពន្យារភាពចាស់។


We're OPEN

Lowell Primary Care Center
OPEN DURING COVID-19 PANDEMIC

Telehealth

Primary Care & Behavioral Health




មណ្ឌលពិនិត្យសុខភាពឡូវែល
បន្តបើកទ្វារបំរើសេវាសុខភាពជូនអ្នកជំងឺទាំងអស់ក្នុងសហគមន៍
ក្នុងកំឡុងពេលនៃការរីករាលដាលនៃជម្ងឺ COVID-19
តាមរយៈ Telehealth
សេវាផ្នែកពេទ្យគ្រួសារនិងសុខភាពផ្លូវចិត្ត

Call: (978) 455-7992



We're OPEN

Lynn Primary Care Center
OPEN DURING COVID-19 PANDEMIC

Telehealth

Primary Care & Behavioral Health




មណ្ឌលពិនិត្យសុខភាពលីន
បន្តបើកទ្វារបំរើសេវាសុខភាពជូនអ្នកជំងឺទាំងអស់ក្នុងសហគមន៍
ក្នុងកំឡុងពេលនៃការរីករាលដាលនៃជម្ងឺ COVID-19
តាមរយៈ Telehealth
សេវាផ្នែកពេទ្យគ្រួសារនិងសុខភាពផ្លូវចិត្ត

Call: (781) 780-7755

# ព័ត៌មានថ្មីពីកូវីត១៩ : រដ្ឋម៉ាសាជូសេតចាប់ផ្តើម បើកសេដ្ឋកិច្ចឡើងវិញក្នុងដំណាក់កាលទី II

ដោយខ្មែរផុស ស.រ.អា

ប៉ូសស្តុនៈ រដ្ឋបាលរបស់លោក បាកឃ័រ ផូលីតូ (Baker-Polito) បានប្រកាសកាលពីខែមុនក្នុងការបើកនូវសេដ្ឋកិច្ចឡើងវិញដំណាក់កាលទីII របស់រដ្ឋបន្ទាប់ពីមានការបិទអស់រយៈពេលជិតបួនខែកន្លងទៅដើម្បីកាត់បន្ថយការរីករាលដែលនៃការឆ្លងជំងឺកូវីត ១៩។

បើយោងតាមសេចក្តីរាយការណ៍របស់រដ្ឋក្នុងដំណាក់កាលទី II នេះ មានអាជីវកម្មបួនសំខាន់រួមមានភោជនីយដ្ឋាន, ការិយាល័យ, ហាងលក់រាយ និងសេវាបំរើអតិថិជនដូចជា-ហាងក្រចក, ម៉ាសសាជាដើមដែលត្រូវអនុញ្ញាតឱ្យបើកឡើងវិញតែត្រូវអនុវត្តន៍ទៅតាមការការណែនាំពីស្តង់ដាសុវត្ថិភាពរបស់មជ្ឈមណ្ឌលត្រួតពិនិត្យ និងបង្កាជំងឺឆ្លង (CDC)។

បើតាមការណែនាំរបស់រដ្ឋ ភោជនីយដ្ឋានអាចបើកឡើងវិញដោយលក់ជូនអតិថិជននៅខាងក្នុងហាងតែមានចំនួនកំណត់ ហើយត្រូវការរក្សាគំលាតពីគ្នា។ តុអាហារត្រូវរៀបចំឱ្យឆ្ងាយពីគ្នា ហើយរាល់ការរៀបចំពិធីជប់លាងត្រូវតំណត់មនុស្សមិនឱ្យលើសពី ៦ នាក់នោះទេ។ ចំណែកបារីវិញអតិថិជនមិនអាចអង្គុយនៅខាងក្នុងខាងនោះទេ ត្រូវរៀបចំកន្លែងនៅខាងក្រៅ។

ចំណែកការិយាល័យវិញ គឺអនុញ្ញាតឱ្យបានតែក្នុងក៏រិត ២៥% ទៅ ៥0% ប៉ុណ្ណោះ។ ទន្ទឹមនឹងនេះដែរ ហាងក្រចក, ហាងម៉ាសា និងហាង



ថែរក្សាស្បែកជាដើម ត្រូវរក្សាគំលាតពីគ្នា ៦ ហ្វីត ហើយត្រូវរក្សាអណាម័យ។ សម្រាប់ហាងលក់រាយវិញ បន្ទប់លសម្លាកបំពាក់វិញត្រូវតែមានការណាត់ជាមុនទើបអាចលសម្លាក់បំពាក់បាន

តទៅទំព័រទី ១២

# Reopening Massachusetts: Baker- Polito Administration Initiates Transition to Second Phase of Four- Phase Approach

BOSTON — The Baker-Polito Administration today announced that Phase II of the Commonwealth's reopening plan will begin on June 8th. Businesses and sectors set to begin opening in Phase II are subject to compliance with all mandatory safety standards. On May 18, the Administration released a four-phased plan to reopen the economy based on public health data, spending at least three weeks in each phase. Key public health data, such as new cases and hospitalizations, has been closely monitored and seen a significant decline allowing for Phase II to begin on June 8th.

The public health dashboard designating the progress of key COVID-19 data metrics has been updated to reflect the number of COVID-19 patients in Massachusetts hospitals to green, indicating a positive trend.

Since mid-April, the 7-day average for the positive COVID-19 test rate is down 82 percent, the 3-day average of hospitalized patients is down 55 percent, and the number of hospitals in surge is down 76 percent.

A total of 630,000 viral COVID-19 tests have been completed, and testing continues to increase throughout the state.

The following businesses will be eligible to reopen in Step One of Phase II on June 8, with contingencies:

- Retail, with occupancy limits;
- Childcare facilities and day camps, with detailed guidance;
- Restaurants, outdoor table service only;
- Hotels and other lodgings, no events, functions or meetings;
- Warehouses and distribution centers;
- Personal services without close physical contact, such as home cleaning, photography, window washing, career coaching and education tutoring;
- Post-secondary, higher education, vocational-tech and occupation

Read Page 12

# CITY OF LOWELL CORONAVIRUS DATA REPORT

June 19, 2020

TOTAL CASES: 2,821
DEATHS: 126
HOSPITALIZED: 326
RECOVERED: 1,798

## DISTRIBUTION BY NEIGHBORHOOD

| | | | |
|---|---|---|---|
| Acre | 246 | Lower Belvidere | 84 |
| Back Central | 159 | Lower Highlands | 278 |
| Belvidere | 167 | Pawtucketville | 471 |
| Centralville | 512 | Sacred Heart | 151 |
| Downtown | 149 | South Lowell | 86 |
| Highlands | 476 | Unknown | 42 |

## DISTRIBUTION BY AGE




## DISTRIBUTION BY GENDER




## DISTRIBUTION BY RACE




**Other** indicates an individual that may not identify with any of the standarized classifications
**Missing/Unknown** indicates individuals that declined to provide information, or that data was not captured for during the interview process.

**Information above is current as of 8:00 am on 6/19/2020.** Data for this report is based on information available to the Lowell Health Deprtment at a single point in time. Case counts and individual data points change throughout the day as new cases are added, data cleaning occurs (i.e. removal of duplicate reports), and updated demographic information is obtained.

"ចក្ខុវិស័យ"

# ប្ញីត្បិត"កូវិដ១៩"សាហាវ តែពិភពលោកនឹងនៅតែប្តូរផ្លាស់

ដោយ ពិន សំខុន

ឡូវែល-ថ្ងៃទី១៥មិថុនា២០២០

ព្រះសុរិយាទើបត្រឡប់មកដុតកំដៅសហរដ្ឋអាមេរិក អឺរ៉ុប ឡើងវិញបន្ទាប់ពី លោកទៅនៅភាគខាងត្បូងអស់រយៈពេល៦ខែមក។ ក្នុងរយៈពេលនោះ កូវិដ១៩ ជាមេរោគសម្លាប់មនុស្សដ៏កំណាចមួយបានបង្ហាញស្នាដៃយកជីវិតមនុស្សអស់ជាង១លាននាក់។ បើទោះជាមេដឹកនាំប្រទេសជាច្រើន បានខិតខំតស៊ូយ៉ាងប្តូរផ្តាច់យ៉ាងអស់សង្ឃឹម ដោយសារគ្មានថ្នាំព្យាបាលដើម្បីទប់ទល់នឹងការរាតត្បាតនៃកូវិត១៩នេះ ដោយបិតទ្វារប្រទេសបិតទំនាក់ទំនងមនុស្សបិតរោងចក្រ បិតចរាចរ បិទទាំមន្ទីរពេទ្យ...គឺទប់ដើម្បីកុំឱ្យចម្លងជម្ងឺពី១ទៅ១តែប៉ុណ្ណោះ, ពិភពលោកក៏បានក្លាយទៅជារហោដ្ឋានស្ងាត់ឈឹងតាំងពី៣-៤ខែកន្លងមកនេះ។ ការប្រឹងប្រែងនោះបានធ្វើឱ្យគេរកឃើញវិធីកាពារបែបបូរមបូរាណខ្លះហើយ ដោយកុំឱ្យមនុស្សនៅជិតគ្នាពេកលាងដៃឱ្យបានញឹកញាប់ពាក់របាំងមុខកុំឱ្យឆ្លងតាមច្រមុះនឹងមាត់ ថែមទាំងមានការផ្លាស់ប្តូរទម្លាប់រស់នៅមានសំអាតទីកន្លែង, របៀបហាត់ប្រាណ, នឹងបរិភោគម្ហូបអាហារ... ទើបតែកំដៅព្រះសុរិយាត្រឡប់មកវិញនារដូវក្តៅនេះ ទើបមានការបើកទីក្រុងមកវិញខ្លះ មានមនុស្សម្នាចេញមកក្រៅខ្លះហើយ ពីព្រោះគេថា "កំដៅថ្ងៃវាជួយសម្លាប់មេរោគ" ជាមួយគ្នានឹង




ទូរស័ព្ទ 5G សម្រាប់អនាគត

ព័ត៌មានថា "ថ្នាំព្យាបាលរកឃើញហើយតែមិនទាន់ដាក់ឱ្យប្រើ"បាន ហើយថា "នៅចុងឆ្នាំ២០២០នេះ នឹងផ្តើមមានការវិវត្តន៏បច្ចេកទេសនឹងសេដ្ឋកិច្ចដ៏សម្បើម ដែលនឹងប្តូរជីវភាពរស់នៅរបស់មនុស្ស" យ៉ាងច្រើនបានទៀតផង។

**តើ"កូវីដ១៩"កើត មកពីណា?**

កាលពីដំបូងគេថា "ជាមេរោគធម្មជាតិបានបង្កើតឡើង" ហើយបានផ្ទុះជាដំបូងនៅប្រទេសចិន នាទីក្រុងសេដ្ឋកិច្ចមួយឈ្មោះ"វូហាន" បណ្តាលឱ្យមានមនុស្សស្លាប់រង្គាល ហើយអជ្ញាធរចិនបានបិទក្រុងនេះមុនគេ។ បន្ទាប់មកក៏រាតត្បាតទៅកូរ៉េទៅអ៊ីតាលីទៅអាស៊ីនឹងអឺរ៉ុបកណ្តាលទៅអឺរ៉ុបទៅអាមេរិកទៅអាហ្វ្រិក...។ប៉ុន្តែក៏មានអ្នកវិទ្យាសាស្ត្រខ្លះថា"កូវិដ១៩"នេះជាមេរោគសិប្បនិមិត្តក៏សាងឡើង សម្រាប់ "ធ្វើសង្គ្រាមជីវសាស្ត្រ" ដែលគេសង្ស័យថា"ចិនជាអ្នកបង្កើតកូវិដ១៩"។ ដំណឹងនេះបានធ្វើឱ្យប្រទេសជាច្រើន មានប្រមាណ ១០០ប្រទេស ហើយ



រថយន្តគ្មានមនុស្សបើក បើកបរលើផ្លូវធម្មតា

ដែលបានប្តឹងទាមទារឱ្យអ.ស.ប.ស្វែងរកការពិត ហើយក្នុងចំនួននោះ ក៏មានប្រទេសរុស្ស៊ីមួយដែរ តែចិនមិនទាន់ឆ្លើយនៅឡើយទេ... គេនៅពុំទាន់ដឹងនៅឡើយថា តើអ.ស.ប. នឹងផ្តើមស៊ើបអង្កេតនៅពេលណានៅឡើយនោះទេ។

**តើនឹងមានអ្វីប្តូរផ្លាស់នៅក្រោយកូវិដ១៩?**

កូវិដ១៩ បានបញ្ឈប់ដំណើរសេដ្ឋកិច្ចស្ទើរគ្រប់កន្លែងនៃពិភពលោក តែប្រជាជាតិទាំងអស់ បែរជានៅតែមានសេចក្តីសង្ឃឹម យ៉ាងមាំថា"អ្វីៗនឹងប្តូរផ្លាស់យ៉ាងសម្បើម បន្ទាប់ពី "កូវីដ១៩"នេះទៅ, តើហេតុអ្វី? ពីព្រោះគេមិនបានឈប់ តាមការគម្រោមកំហែងរបស់កូវិដ១៩នោះទេ! ដោយសារតែសេចក្តីសង្ឃឹមថា នឹងមាន"ការផ្លាស់ប្តូរជាវិជ្ជមាន"នោះ វានៅក្នុងកណ្តាប់ដៃពួកគេរួចទៅហើយ ។(នៅមានត)



តមកពីទំព័រទី ០១

# លោក កឹម សុខា អាចត្រឡប់ចូល....

**តើដំណោះស្រាយ កឹម សុខា នោះជាអ្វី?**

កឹម សុខា មិនបានបង្ហាញនូវអ្វី ដែលនាំឱ្យជាប់អន្ទាក់កំណាចរបស់ ហ៊ុន សែន សូម្បីតែបន្តិចឡើយ... អន្ទាក់នោះគឺ ហ៊ុន សែន ក៏ដឹងពីបំណងរបស់ កឹម សុខា ចង់ត្រឡប់មកសេវានយោបាយដោយកម្លាំងផ្ទៃក្នុងនឹងកម្លាំងប្រជាធិបតេយ្យរួមគ្នា” ថ្វីត្បិតតែគ្មាន សម រង្ស៊ី ដែលបានភ្លាត់ស្នៀតជាបន្តបន្ទាប់ របូតចេញពីសង្គ្រោះជាតិទៅហើយក្តី ក៏ម្ចាស់ឆ្នោតនាថ្ងៃខាងមុខនឹងគាំទ្រឱ្យ“ព្រលឹងសង្គ្រោះជាតិ”ក្នុងរូបភាព ដែលគេអាចជឿបាន - កឹម សុខា គឺជារូបភាពនោះឯង តែ ហ៊ុន សែន មិនទាន់ចាប់ផ្ទាក់បាននៅឡើយ។ ហេតុនោះហើយ ទោះជានៅក្នុងដង្កាប ដែលបង្កើតឡើង ដោយ កឹម សុខា ក្តី ហ៊ុន សែន មានការលំបាកនឹងពន្យាពេលដោះលែង កឹម សុខា ឱ្យមានសេរីភាពនាពេលនេះណាស់ ពីព្រោះខ្លួនជឿថាបើដោះលែងពេលនេះ លោក សុខា នឹងមានពេលគ្រប់គ្រាន់សម្រាប់រៀបចំគណបក្សប្រឆាំងឡើងវិញបានផង ហើយក៏មានពេលសម្រាប់សម្លាប់ សម រង្ស៊ី ដែលតែងតែរកឱកាសពន្លិចលោកសុខា ជំនួសដៃលោក ហ៊ុន សែន មិនដែលស្រាកឡើយទៀតផង។ ថ្វីត្បិតតែរងគ្រោះច្រើនដងក្នុងប្រទេសដោយទង្វើ សម រង្ស៊ី ពីក្រៅប្រទេស នា ២-៣ឆ្នាំចុងក្រោយ កឹម សុខា ខំមាត់ អត់



ដង្ហើមមិនបានធ្វើឱ្យនរណាម្នាក់ចាប់ផ្ទាក់ ឬដឹងពីបំណងពិតរបស់លោកបានឡើយ សូម្បីតែខឹងចំពោះ រង្ស៊ី វិញក៏មិនដឹងដែរឬ តែចំពោះ ហ៊ុន សែន ដែលជាអ្នក“ញាក់ខ្សែ” បែរជាមិនដឹងជា “ញាក់ខ្សែ”ពេលណាដែរនោះ ទើបវាសំខាន់!

**មេរៀនពីអតីតកាលៈ**

ងាកត្រឡប់ទៅក្រោយវិញ កឹម សុខា ហាក់មិនបានទទួលការចោទប្រកាន់ពីអ្នកសង្កេតការនានា ពីការទទួលយកអាសនៈ“ចុះចាញ់៥៥” ពីគណបក្សប្រជាជននោះទេ, តែផ្នែកខាង សម រង្ស៊ី វិញៈមាន, ពីព្រោះខាងនោះសម្បូរក្រុម “ស៊ីពែរ”គេដោយមិនខ្មាសអៀនច្រើនគ្នា។ សង្គ្រោះជាតិឆ្នាំ២០១៣នោះ សម រង្ស៊ី មានអំណាចខ្លាំងណាស់ ដោយកូតាខ្លួនក៏ធំ ដំណាងរាស្ត្រខ្លួនក៏ច្រើន ធ្វើអ្វីស្រេចតែចិត្តមិនខ្វល់ពីយោបល់របស់សម្ព័ន្ធមិត្តខ្លួននោះទេ, ម្លោះហើយគេប្រកាសឱ្យចាញ់ ក៏សុខចិត្តចាញ់, ក៏ប៉ុន្តែប្រជាជាតិបានកត់សម្គាល់“ជនក្បត់” នៅក្នុងបក្ស ដែល “ឈ្នះក៏មិនដឹងឈ្នះ”ជាមួយនឹងប្រជារាស្ត្រចេញមកគាំទ្រកកកុញ ក៏“មើលមិនឃើញ” នោះបានវាពិសេស។

**នរណាជាអ្នកធ្វើឱ្យសង្គ្រោះជាតិចាញ់?**

ឆ្នាំ២០១៣នោះ ជាមេរៀនដ៏សំខាន់មួយសម្រាប់ការបោះឆ្នោតខាងមុខ គឺត្រូវ“ចងជើងពួកក្បត់ឱ្យជាប់”, លោក សុខា នឹងមន្ត្រីឯទៀតដែលបានរួចខ្លួនពី“ការចាញ់សម្បត់ខ្លួនឯង” នឹងដណ្តើមយកជ័យជំនះតែម្នាក់ឯងបានដោយការរួមសម្បាច់ពិតប្រាកដពីមិត្តរួមគំនិត រួមឧត្តមគតិ រួមភាពស្មោះត្រង់។ បើប្រជាពលរដ្ឋមិនបានគាំទ្រ សម រង្ស៊ី នាពេលខាងមុខ គឺមិនមែនពលរដ្ឋក្បត់នឹង សម រង្ស៊ី នោះទេ គឺសម រង្ស៊ី ទៅវិញទេ ដែលជាអ្នកក្បត់នឹងអតីតៈសង្គ្រោះជាតិនោះ ដូច្នេះបើ រង្ស៊ី ចូលនិវត្តន៍ពេលនេះ ទើប ហ៊ុន សែន “បារម្ភខ្លាចចាញ់”ខ្លះ តែបើមិនចូលនិវត្តន៍ទេ ហ៊ុន សែន នឹងប្រើ រង្ស៊ី ឱ្យ “ស៊ីឈ្នួលចាញ់”ទៀត។

**សង្គ្រោះជាតិនឹងឈ្នះរបៀបណា?**

ចាញ់ទាល់តែប្រទេសកម្ពុជាបច្ចុប្បន្នក្លាយជាមានអាគារស្កឹមស្កៃមែន មានផ្លូវកៅស៊ូខ្វាត់ខ្វែងមែន

តទៅទំព័រទី ១១



# Summer Life in New England During Covid-19 Pandemic

*From Front Page*

We traveled up and down the coast between Newport Beach, Rhode Island, to Cape Cod, Massachusetts, to New Castle, New Hampshire and to Ogunquit & Portland, Maine. I will share you what I have learned so far so that you may exercise cautionary steps in taking your family out this summer.





Windmill Beach, South Yarmouth, MA

The "new normal" that we all must adjust to in order to navigate our every day life is that we all now have to look at everything in a new way.

As States begin to reopen partially, restaurants, beaches, etc, we found ourselves more comfortable going into unpopular destinations where fewer people travel. Traveling by car help us find places which would allow us to camp for the day, such as today, we found an island which we normally wouldn't venture to, Cape Elizabeth. There we visited the Port William State Park where many panic tables with ocean views, beaches, and a couple beautiful lighthouse of Portland, Maine's coastline.



Downtown Portland, Maine closed several streets for restaurants to serve outdoors dining.



Portland Head Light, Cape Elizabeth, Maine

Hotel stays. We bring a bottle of 70% alcohol and spray everything after entering our room including the remote control of a tv, the keys, and door knobs. We wear masks when we were near people until we reached our destination and being without people around. It felt safe. We keep an alcohol spray in the car, wash our hands anytime after we go out to the market. I keep an alcohol spray in my purse and spray our hands before and after we eat. We chose take-out foods when restaurants are full, even with 6 ft distant apart between tables. We prefer to sit outside where everyone is at least 10 feet apart. So far we have not run into any issue about spacing with a few exception such as downtown Portland, Maine and Newport Beach where many young people are hanging out. This maybe explaining why Covid-19 cases are spreading amongst younger people under 40 years old. According to Center for Disease Control, 900 thousands cases are the young people between age of 18-44, 700 thousands cases are the people between age 45-64, and 200 thousands people are between age 65+ who are infected by the covid-19.

While in Maine, we found everyone more relaxed, beside service workers, only a few people were wearing masks, and we felt it was almost scary. However, we can understand in a state of population 1.3 million, only 200 died of the covid-19, and over 3,000 cases total, people don't feel the threats of the corona virus. Similar to the population in New Hampshire, there are 5,600 cases and 365 deaths. Comparing to Massachusetts, with 6.9 million people, the cases are staggering more than 5 times higher. While in Rhode Island we also found the number of infected people to be 16,000 with 900 deaths. The total population of the state is 1 million.

Although the curve in Massachusetts is flattening from 5,000 cases a day in the third week of April to 233 cases a day as of June 26, the experts are saying a second wave is coming. We hope Massachusetts will not be affected by it, but we will never know for certain.

There are 2.5 million cases in the United States, with 125,000 people died. The cases are going up in the states including Florida, there are 9,000 people infected in one day on June 26 as state reopened for a few weeks, the second wave struck. In Texas, 1 in 10 people are infected. States of Arizona and California are also going up. If you have travel plans to these states, you may have to self quarantine upon return to states like Connecticut, New Jersey, and New York.

Last but not least, I recommended our readers to stay local in New England this summer and avoid taking flights unless it's an necessary. The air confinement in the plane is what make the virus lingering around; even though with empty middle seats, there aren't enough social distancing and you should be wearing masks at all time. The "new normal" here we all should look into is the simple way of life how family used to be like when there were limited bars, restaurants, theatre and sports. Consider it as a luxury in the time of covid-19 to be able to do any of these activity above and practice social distancing when you do so. When you don't feel well, stay at home. When you feel the flu-like symptoms including the lost sense of smell, you should get tested for the covid-19. Experts are saying that there are ten times higher than 2.5 millions Americans infected now because the limited testing capacity. So be vigilant. There are 10 millions people infected by the covid-19 in world in the last six months and already half million people died globally. I urge everyone to continue practice social distancing and be safe. This is far from over.

តមកពីទំព័រទី ០៩

## លោក កឹម សុខា អាចត្រឡប់ចូល....

ប៉ុន្តែរាស្ត្រជាង៨០ភាគរយ នៅតែជាអ្នកក្រីក្រ ជាអ្នកខ្វះចំណីអាហារ ខ្វះការងារក្នុងស្រុកធ្វើ ខ្វះការគ្រប់គ្រងបែបសេរី ។ ដូច្នេះអ្នកស្រុកទាំង៨០%នោះហើយ ដែលនៅតែភក្តីចំពោះ "ព្រលឹងគណបក្សសង្គ្រោះជាតិ"តែដដែល បើទោះជាលោក កឹម សុខា ដឹកនាំគណបក្សឈ្មោះអ្វីក៏ដោយ, ពីព្រោះថា មនុស្សល្អ ឬគណបក្សប្រសើរ វាមិនសំដៅទៅសំលៀកបំពាក់ល្អ ឬក៏ចំណេះខ្ពង់ខ្ពស់ ឬក៏ពូកែរនិយាយ នោះទេ, នោះពីព្រោះតែ"ពលរដ្ឋចង់ប្តូររបប" ។

មកទល់ថ្ងៃនេះទៅហើយ ប្រមុខគណបក្សប្រឆាំង កឹម សុខា មិនបានឱ្យដឹងពីបំណងនយោបាយណាមួយឱ្យគេឯងបានដឹងឮនៅឡើយទេ, តែក៏មានអតីតដំណាងរាស្ត្រកូតារបស់លោក សុខា ខ្លះ ក៏បានចុះឈ្មោះសុំធ្វើនយោបាយទៅហើយដែរ ទៅតាមគន្លងនៃច្បាប់ថ្មី ដែលជាសញ្ញាថា"សង្គ្រោះជាតិ"កំពុងចេញមុខមកហើយ ។

ប្រឆាំងក៏មិននិយាយគាំទ្រក៏មិនថា លោក កឹម សុខា ធ្វើឱ្យគេគិតថា តើ កឹម សុខា រង់ចាំឱ្យគេដាក់ទានគណបក្សសង្គ្រោះជាតិឱ្យមកវិញតាមការទាមទាររបស់សហគមន៍អន្តរៈជាតិនោះ ឬ? មិនបានទេ! មិនអាចមានអន្ទាក់តែគ្រប់កន្លែងនោះទេ! កាលពីឆ្នាំ២០១៣ ហ៊ុន សែន ធ្វើ"ភ្នែកមាន់ស្មោ"ដោយសារសង្គ្រោះជាតិម្តងហើយតើ? នៅភូមាគណបក្សកងទ័ពក៏ភ្លាត់ចាញ់"អូនសាន់ស៊ូជី" រហូតមកដល់ពេលនេះទេតើ? ដូច្នេះពលរដ្ឋខ្មែរ ម្ចាស់ឆ្នោតត្រូវតែដឹងឱ្យបានមុនជាយូរថា"សង្គ្រោះជាតិ" បានបង្ហាញខ្លួនចេញមកហើយ! សូមកុំរង់ចាំរហូតដល់ពេលប្រថុចញ្ចុចឱ្យសោះ, បើរង់ចាំសន្លឹក "អាត់" កឹម សុខា តែម្នាក់ គឺអាចនឹងយឺតយ៉ាវ ដូច្នេះត្រូវបង្កើតសន្លឹក"អាត់" អ៊ូ ចាន់រដ្ឋ "អាត់" ប៉ុល ហំ ឬក៏"អាត់"សុន ឆៃ ឬក៏"អាត់"គង់ គាំ... ឱ្យព្រោងព្រាត ទើបរាស្ត្រហ៊ានចេញមកអបអរសាទរ, ចំណាកស្រុករាប់លាននាក់ នឹងត្រឡប់មកលើកទង់នៃជ័យជំនះ នៅឆ្នាំ២០២១-២២ ជាមួយព្រលឹងសង្គ្រោះជាតិនឹងព្រលឹងអ្នកតស៊ូ ដើម្បីសេរីភាពនឹងលទ្ធិប្រជាធិបតេយ្យទាំងអស់ជាមិនខាន ។

ចុងបញ្ចប់ការតស៊ូជាង៣០ឆ្នាំ នៅកម្ពុជាមិនជាការអត់ប្រយោជន៍ទេ លោក កឹម សុខា អាចក្លាយទៅជា"ម៉ង់ដេឡា"ម្នាក់ដែរ ពីព្រោះថាការរង់ចាំរបស់លោកជាយូរលង់យ៉ាងប្រុងប្រយ័ត្ននេះ ក៏ជាគុណសម្បត្តិសម្រាប់ឯកភាពនៃក្រុមបក្សប្រឆាំងនឹងសហគមន៍អន្តរជាតិ ដែលគេនឹងចេញប្រកួតគ្នាយកឈ្នះចាញ់លើ ហ៊ុន សែន ដោយបំណង"សន្តិវិធី" មិនអាចប្រកែកបានឡើយ ។













# ម្ចាស់ភោជនីយដ្ឋានជួយគ្រួសាររងគ្រោះនៅឡូវែល

ដោយ ពិន សំខុន

នៅឡូវែលតំបន់ដែលមានខ្មែររស់នៅច្រើនជាងគេ នាឆ្នេរខាងកើតនៃសហរដ្ឋអាមេរិក ក៏មានអ្នករងគ្រោះដោយសារមេរោគ"កូវីដ១៩"ដែរ, មិនមានចំនួនច្រើនទេ តែទោះជាតិចតួចក្តីគ្រួសារអ្នកជម្ងឺខ្មែរ មិនចូលចិត្តឱ្យគេដឹងឮ ពីព័ត៌មានពីជម្ងឺនោះទេ ។

ម្ចាស់ភោជនីយដ្ឋានមួយ ដែលគេស្គាល់ឈ្មោះ ថា "សាំព្លីខ្មែរ" នៅ២៦ផ្លូវលីនកូន តាមរយការណែនាំរបស់សមាគម"អេសេឡិក ASALEC" ដែលបានផ្តល់ដំណឹងថា មានគ្រួសារខ្មែររងគ្រោះដោយសារជម្ងឺដែលរាលសាយក្នុងពិភពលោកនេះ កំពុងតែផ្តាច់ខ្លួនពីសង្គមមនុស្សដើម្បីព្យាបាលជម្ងឺដោយខ្លួនឯង។ លោកសម្បត្តិនឹងភរិយាជាម្ចាស់ហាង ក៏មានចិត្តសទ្ធាបានផ្តល់ជាម្ហូបអាហារចម្អិនស្រាប់ប្រចាំថ្ងៃ ដ៏ឈ្ងុយឆ្ងាញ់ពិសារចំនួន៥ថ្ងៃ ផ្តើមពីសប្តាហ៏មុន រហូតដល់ថ្ងៃ"បុណ្យបីតា" ជូនគ្រួសារទាំងនោះ ដើម្បីផ្តល់ភាពកក់ក្តៅជាមិត្តភាពពីសហគមន៏ ដែលធ្លាប់ពិបាកស្រណុកជាមួយគ្នាជាច្រើនឆ្នាំមកហើយ ។



អាសេឡិចទៅទទួលយកម្ហូបដើម្បីចែកពីភោជនីដ្ឋានខ្មែរ ជាម្ចាស់អំណោយ



រិទ្ធី សៅ សមាគមអាសេឡិច កំពុងដើរចែកម្ហូបដល់គ្រួសាររងគ្រោះ



គ្រួសាររងគ្រោះមកទទួលម្ហូបពី ពិន សំខុន អាសេឡិច

រៀងរាល់លើក ដែលសមាជិកអេសេឡិកនាំយកម្ហូបចំណីទៅជូនគ្រួសារអ្នករងគ្រោះ យើងបានឃើញភាពរីករាយ អបអរសាទរ របស់គ្រួសារផ្តាច់ខ្លួន ដែលបានផ្តាំផ្ញើរអំណរគុណដ៏ជ្រាលជ្រៅជូនដល់ម្ចាស់អំណោយវិញផង ។ បន្ថែមពីអំណោយជាម្ហូបចម្អិនស្រាប់ សមាគមបានឧបត្ថម្ភដល់សមាជិកសកម្មជាប្រាក់៣០០ដុល្លារផង ។

សមាគមអេសេឡិកជាសមាគម Non-profit មិនរកប្រាក់ចំណេញស្ថិតនៅ ៣២៥ Chelmsford st. Lowell មានបំណងជួយលើកដំកើងជីវភាពសហគមន៏ជនជាតិអាស៊ីអគ្នេយ៏, មានសកម្មភាពសំខាន់ៗ ធ្វើនៅឡូវែលនឹង នៅកម្ពុជា ហើយដែលបច្ចុប្បន្នជួយដោះស្រាយប្រជាជនក្នុងបញ្ហាទប់ទល់នឹង"កូរ៉ូណាវ៉ាយរីស" ជួយបញ្ហាសេដ្ឋកិច្ច សង្គមកិច្ច អន្តោប្រវេសន៏សិក្សាធិការគ្រួសារ...។ល។ ប្រជាពលរដ្ឋនៅឡូវែលអាចរកជំនួយនានាបាន ដោយទូរស័ព្ទ ទៅលេខ ៩៧៨ ៩៤២ ៨៤៩០ ពិន សំខុន ឬក៏លេខ ៩៧៨ ៦៥៤ ១៧៣៤ រិទ្ធី សៅ ដើម្បីបានព័ត៌មានបន្ថែម ។

Continued from page 07

## Reopening Massachusetts: Baker- Polito

schools for the purpose of completing graduation requirements;

- Youth and adult amateur sports, with detailed guidance;
- Outdoor recreation facilities
- Professional sports practices, no games or public admissions;
- Non-athletic youth instructional classes in arts, education or life skills and in groups of less than 10;
- Driving and flight schools
- Outdoor historical spaces, no functions, gatherings or guided tours;
- Funeral homes, with occupancy limits The following businesses will be eligible reopen in Step Two of Phase II at a later date to be determined:
- Indoor table service at restaurants
- Close-contact personal services,with restrictions, including:
- Hair removal and replacement
- Nail care
- Skin care
- Massage therapy
- Makeup salons and makeup application services
- Tanning salons
- Tattoo, piercing and body art services
- Personal training, with restrictions

Full list and safety protocols available at www.mass.gov/reopening.

The Baker-Polito Administration also released other sector specific guidance:

- Close Contact Personal Services
- Sectors Not Otherwise Addressed

Health care providers may also incrementally resume in-person elective, nonurgent procedures and services, including routine office visits, dental visits and vision care subject to compliance with public health and safety standards.

All other in-person medical, behavioral health, dental and vision services may also resume on June 8th, except for elective cosmetic procedures and inperson day programs, which will be included in Phase III. Telehealth must continue to be utilized and prioritized to the greatest extent possible, whenever feasible and appropriate.

Limited reopening of visitation will also begin, and all visitation is subject to infection control protocol, social distancing and face coverings. Given the diversity of facilities and programs, there are specific timetables for visitation, and congregate care programs will be reaching out to families with specific details on scheduling visits.

តមកពីទំព័រទី ០៧

## ព័ត៌មានថ្មីពីកូវីត១៩: រដ្ឋម៉ាសាឈូសេត

ហើយអតិថិជនទាំងអស់តម្រូវឱ្យពាក់ម៉ាស និងរក្សាគំលាតពីគ្នា។ សម្រាប់មជ្ឈមណ្ឌលថៃរក្សាសុខភាពវិញ បើកដំណើរការផ្តល់សេវាដូចជាការណាត់ជួបជាមួយអ្នកជំងឺ, ពិនិត្យធ្មេញ និងភ្នែក តែត្រូវអនុឡោមទៅតាមស្តង់ដារសុវត្ថិភាព និងសុខភាព។

គួរបញ្ជាក់ថា រហូតមកដល់ពេលនេះ ចំនួនសរុបនៃតេសជំងឺកូវីត ១៩ មានចំនួន ៦៣០, ០០០នាក់ ហើយការធ្វើតេសនេះ នៅតែបន្តកើនឡើងទូទាំងរដ្ឋ។ ចាប់តាំងពីពាក់កណ្តាលខែមេសាមក ចំនួនអ្នកធ្វើតេសដែលមានជំងឺកូវីត១៩ មានការធ្លាក់ចុះដល់ទៅ ៨២% ហើយចំនួនអ្នកជំងឺចូលសម្រាកក្នុងមន្ទីរពេទ្យវិញ ក៏មានការថយចុះដល់ទៅ ៥៥%។ សម្រាប់ទីតាំ ងធ្វើតេស្តរហ័សជំងឺកូវីត១៩ នៅទីតាំងជិតអាគារ Crosspoint នៅក្នុងក្រុងឡូវែល នឹងត្រូវបិទចាប់ពីថ្ងៃទី ២៧ ខែមិថុនា នេះទៅ ដោយសារតែចំនួននៃអ្នកមកធ្វើតេស្តមានការធ្លាក់ចុះក្នុងរយៈពេលប៉ុន្មានសប្តាហ៏ចុងក្រោយនេះ។



# KhmerPost USA, LLC
# សារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិក



**អគ្គនាយក សុបិន្ត ពិន**
Soben Pin, Co-Founder|Publisher
Office: 978 677-7163 | Cell: 978-656-8141
Soben@khmerpostusa.com



**និពន្ធនាយកខ្មែរ** Khmer Editorial
និពន្ធនាយក ពិន សំខុន
Roger Samkhon Pin, Co-founder|Editor
978-942-8490 | pinsamkhon@gmail.com

**ផ្សាយពាណិជ្ជកម្ម សុបិន្ត ពិន**
Advertising Contact
Soben Pin
Cell: 979-656-8141
Soben@khmerpostusa.com

**អ្នកនិពន្ធកិត្តិយស** Staff Writer| Translator
Sokharath Koy | Khmerpostusa@gmail.com

**ច្នៃសោភ័ណ្ឌភាព** Design Artist
Heng Chhun Leng

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.
Follow us: Facebook | Twitter KhmerpostUSA



# សមាគម"អាសេឡិច"មានអ្នកជួយ ធ្វើសំណុំរឿងជួយដល់អ្នកអត់ការធ្វើ

-ពាណិជ្ជករចង់បានប្រាក់ជំនួយជាប្រាក់កម្ចីរបស់រដ្ឋ និងជួយដល់អ្នកដែលមិនបានទទួលស្ទីមេលីស និងឯកសាររដ្ឋបាលផ្សេងៗទៀត ។
-មានសេវាផ្សេងទៀត ដូចជា: ថ្នាក់យកប័ណ្ណបើកបររថយន្ត ថ្នាក់បង្រៀនយកសញ្ជាតិអាមេរិកាំង មានសេវាសុំប័ណ្ណបើកម្ហូបអាហារ
-មានសេវាអន្តោប្រវេសន៍ទៀតផង
សូមទូរស័ព្ទមកសមាគម "អាសេឡិច" ទូរស័ព្ទលេខ 978-942-8490
អាស័យដ្ឋានលេខ: 325 Chelmford St. Lowell





# ការិយាល័យ មេធាវី ចំមាស ស្តាលីយ៉ាណូស

**Law Office of Thomas Stylianos Jr.**
**287 Appleton St. Lowell MA 01852**

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ **978-459-5000 or 800-308-3766**
**www.thomasinlowell.com**



## ក្រុមហ៊ុន ហានធ័រ ខន់ស្រាក់សិន ខូបភ័រេសិន
(HUTTER CONSTRUCTION CORPORATION)

ក្រុមហ៊ុនម៉ៅការសំណង់ទូទៅ
ការដាក់ដេញថ្លៃ
**ស្ថានីយពន្លត់អគ្គីភ័យ ភាញ្ញហោស**
(PINEHURST FIRE STATION)
ដែលមានទីតាំងនៅប៊េលីកា,រដ្ឋម៉ាសាជូសេដ បានទទួលការដាក់ដេញថ្លៃអ្នកម៉ៅការបន្ត ដូចជា: ការងារបេតុង Div. 3 Concrete, ឈើ Div. 6 Woods, ផ្លាសស្ទិច & Composites
Div. 7 Thermal & Moisture លើកលែង
Waterproofing,
ការងារDiv. 8 Openings លើកលែងបង្អួចដែក, កញ្ចក់, និងការដាក់កញ្ចក់
ការងារ Div. 9 Finishes លើកលែងការ ក្រឡាក្បឿង, កំរាលឥដ្ឋ និងការលាបពណ៌,
ការងារ Div. 10 Specialties
ការងារ Div. 11 Equipment
ការងារ Div. 12 Furnishings
ការងារ Div. 14 Fixed Vehicle Service Lifts
ការងារ Div. 31 Earthwork
ការងារផ្នែកខាងក្នុង Div. 32 Exterior Improvements
ការងារទឹកភ្លើង Div. 33 Utilities
**ព័ត៌មានពីគម្រោង**
ការវាយកម្ទេចអាគារដែលមានស្រាប់ និងសាងសង់ថ្មីនូវស្ថានីយពន្លត់អគ្គីភ័យដែលមានទំហំ ១១, ០០០ ការ៉េ ។
**ឯកដេញថ្លៃ:**
- តម្រូវឱ្យមាន MBE nig WBE
- ត្រូវអនុវត្តន៍ MBE contracting goals
- ត្រូវអនុវត្តន៍ Minority employees goals
- បង្ហាញពី MBE និងស្ថានភាព WBE របស់អ្នកជាមួយនិងការដាក់ដេញថ្លៃ ។

កាលបរិច្ឆេទនៃការដេញថ្លៃសម្រាប់អ្នកម៉ៅការបន្ត:
ការដេញថ្លៃអ៊ីមែលមកកាន់ The General Contractor តាមរយ:អាស័យដ្ឋាន jlewis@hutterconstruction.com ត្រឹមថ្ងៃអង្គារទី ៧ ខែកក្កដា ឆ្នាំ២០២០
Hutter Construction Corporation
New Ipswich, NH 03071

**ឯកសារនៃសាងសង់:**
មានឯកសារស្តីពីគម្រោងនិងព័ត៌មានលំអិតពី Jay Lewis តាមរយៈអ៊ីមែល jlewis@hutterconstruction.com
ទូរស័ព្ទលេខ (603) 878-2300
ហ្វាក់ (603) 878-3519
ក្រុមហ៊ុន ហានធ័រ ខន់ស្រាក់សិន ខូបភ័រេសិន គឺជាក្រុមហ៊ុនម៉ៅការដែលផ្តល់ឱកាសស្មើគ្នា និងមិនមានការរើសអើង ។

## HUTTER CONSTRUCTION CORPORATION,

General Contractor
bidding
PINEHURST FIRE STATION
BILLERICA, MA,
is receiving
SUBCONTRACTOR BIDS FOR:
Div. 3 Concrete
Div. 6 Woods, Plastics & Composites
Div. 7 Thermal & Moisture EXCEPT
Waterproofing
Div. 8 Openings EXCEPT Metal Windows, Glass & Glazing
Div. 9 Finishes EXCEPT Tile, Resilient Flooring, Painting
Div. 10 Specialties
Div. 11 Equipment
Div. 12 Furnishings
Div. 14 Fixed Vehicle Service Lifts
Div. 31 Earthwork
Div. 32 Exterior Improvements
Div. 33 Utilities
PROJECT DESCRIPTION
Demolition of existing building and new
construction of an 11,000 SF fire station.
BID NOTES:
- MBE and WBE requirements
- MBE contracting goals apply
- Minority employees goals apply
- Indicate your MBE, WBE status with bid.

SUBCONTRACTOR BID DATE:
Email Bids are due
to the General Contractor at
jlewis@hutterconstruction.com on
Tuesday, July 7, 2020 by end of day.
Hutter Construction Corporation
New Ipswich, NH 03071

CONSTRUCTION DOCUMENTS:
Plans and Specifications are available from
Jay Lewis at jlewis@hutterconstruction.com
Phone (603) 878-2300
Fax (603) 878-3519
Hutter Construction Corporation is an EOE/non-discriminatory contractor.

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare
### Home Care Agency
Group Adults Foster Care Program

**ហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុម គ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។**

*At no Cost to you*

សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកដោយមិនគិតថ្លៃអ្នកនឹងត្រូវបានថែទាំដោយក្រុមបុគ្គលិកខ្មែរដែលមានវិជ្ជាជីវៈពី នើស (Nurse), Case Manager និង Home Health Aide បុគ្គលិកមានសណ្តានចិត្តល្អ ទន់ភ្លន់ និងមានការគោរពទំនៀមទំលាប់ខ្មែរ ។ បំរើសេវាក្នុងតំបន់ Lowell, Lynn, Revere, Boston និងតំបន់ជុំវិញ





**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

- រស់នៅផ្ទះរដ្ឋ
- អាយុ ២២ ឆ្នាំឡើងទៅ
- មាសវែហិលស្តង់ដា

**ផលប្រយោជន៍ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយ ថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីជើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក២៤ម៉ោង

**To be eligibled for GAFC you must:**

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

**Benefits you will get:**

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

## ដើម្បីចុះឈ្មោះសូមទាក់ទងមក

To register, please contact:

Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

"អត្ថបទស្រាវជ្រាវប្រវត្តិសាស្ត្រ"

# ប្រវត្តិនៃសមាគមអ្នកសារព័ត៌មានខ្មែរ"ខេជីអេ"

## អវសាន្តនៃសមាគម KJA Khmer Journalists Association

(KJA = Khmer Journalist Association )

ដោយ ពិន សំខុន **តពីលេខមុន**

ក៏ប្រញាប់ទៅជួយទាន់ពេល,ទំនងជាខ្លាច មានរឿងធំកងចល័តទាំងនោះ តែងប្រញាប់ ចាកចេញពីកន្លែងកើតហេតុជាបន្ទាន់។ ម្នាក់ៗ សុទ្ធតែចង់ប្តូរជីវិត ដើម្បីការពារកាសែតរបស់ ខ្លួន។

ចំណែកឯស្ថានភាពសេដ្ឋកិច្ចរបស់កាសែត វិញ ជាទូទៅអាចរស់ដោយសារវិជ្ជាជីវៈបានដែរ ដូចជាកាសែត "រស្មីកម្ពុជា" មានពាណិជ្ជកម្ម ដែលគេបង់ថ្លៃ ស្ទើរគ្រប់ទំព័រ មានអ្នកយកការ នឹងអ្នកយកព័ត៌មានរាប់សិបនាក់ ហើយយក៏ មានអ្នករកពាណិជ្ជកម្មមានប្រាក់ខែក៏ច្រើនរាប់ សិបនាក់ទៀតដែរ ហើយនៅមាន បង្អែកជាអ្នក នយោបាយបក្សកាន់អំណាចក៏"ខ្នងក្រាស់"ទៀត... ដូច្នេះក៏ក្លាយជាកាសែតជម្រើសទី១ ព្រឹត្តិការណ៍ លេចធ្លោណាមួយ កាសែតនោះអាចលក់បាន ៣, ៤ម៉ឺនច្បាប់ភ្លាមបាន។ នៅកម្ពុជាសម្បូរ ព្រឹត្តិការណ៍លេចធ្លោនោះច្រើនណាស់ ដូចជាបាតុ កម្មប្រឆាំងរដ្ឋាភិបាលទប់ស្កាត់ដោយកម្លាំង ប៉ូលិស, ដូចជាសម្លាប់ ឬចាប់អ្នកកាសែតដាក់ គុក, ការឃោសនាបោះឆ្នោត, ទំនាស់នយោបាយ ប៉ះទង្គិចជាមួយមេបក្សប្រឆាំង សម រង្ស៊ី, ជំលោះ រវាងនាយករដ្ឋមន្ត្រី, ទំនាស់កណ្តាលក្រុងភ្នំពេញ




អ្នកអាននៅតាមតូបលក់កាសែត

រវាងទ័ពគណបក្សប្រជាជន នឹងទ័ពគណបក្ស ហ៊្វុនស៊ិនប៉ិច, ទំនាស់ព្រំប្រទល់ដែនជាមួយនឹង វៀតណាម... ។ល។

ចាប់ពីឆ្នាំ១៩៩៥ទៅ នយោបាយកម្ពុជា តឹងតែងខ្លាំងណាស់ ដោយលោក ហ៊ុន សែន បាន សម្រេចចិត្តដណ្តើមយកអំណាចឱ្យខាងតែប ាន... ប៉ុន្តែអ្នកអានខ្មែរយើង ក៏ចូលចិត្តតាមដាន កាសែតប្រឆាំងរបស់គណបក្ស សម រង្ស៊ី ណាស់ ដែរ គេចេញផ្សាយ តែ៤ ទៅ៨ទំព័រ តែប៉ុណ្ណោះ ប៉ុន្តែគេប្រើ ពាក្យ ឬប្រយោគ មុតស្រួចណាស់ គួរយ៉ាងបកអាក្រាតយ៉ាងហ៊ានដោយមិនខ្លាច នឹងប្តូរជីវិតខ្លួន។ កាសែតទាំង៥,៦ឈ្មោះនោះ មានកាសែតសម្លេងយុវជនខ្មែរ, កាសែតមន សិការខ្មែរ, កាសែតឧត្តមគតិ,... បានបើក សម រភូមិបញ្ចេញមតិប្រឆាំងនឹងគណបក្សប្រជាជន ហើយបានលើកសកម្មភាពនយោបាយ លោក សម រង្ស៊ី ឱ្យក្លាយជា"វីរបុរសរងគ្រោះ" ដែល អាចប្តូរសេចក្តីសង្ឃឹមរបស់ពលរដ្ឋខ្មែរបាន។ ក្រុមនោះ ក៏លក់កាសែត ដែលទោះជាគ្មាន ពាណិជ្ជកម្មក្តី ការបញ្ចេញមតិ ប្រឆាំងអំពើពុក រលួយនយោបាយផ្តាច់ការគ្រួសារបកពួកនិយម នយោបាយបំរើអនាធិគមបរទេស, ក៏បានចំណេញ ប្រាក់ក្រាស់ក្រែលដែរ លក់បានជាមធ្យម ពី៤ ពាន់ទៅ៧ពាន់ច្បាប់ ពេលខ្លះក៏បានរាប់ម៉ឺន ច្បាប់ដែរ។ ក្រុមកាសែតទាំងនោះ ថ្វីត្បិតតែ បង្ហាញការពេញចិត្តសកម្មភាពរបស់ KJA តែ មិនចូលជ្រកក្រោមផ្លាក "សមាគមអ្នកសារព័ត៌ មានខ្មែរ"រនោះទេ។

នៅមានកាសែត"កោះសន្តិភាព" នឹង "ដំណឹងពេលព្រឹក" ជាកាសែតដែលគេចូលចិត្ត អាន ពីព្រោះតែអ្នកនិពន្ធចូលចិត្តសរសេរឡក ឡឺយ ចំអាសចំអូងឥតខោឥតអាវ រៀងលេង ជាមែន រឿងមែន ក៏លេងដាក់គ្នាទៅវិញទៅមក ។ កាសែតកោះសន្តិភាព នៅខាងគណបក្សប្រជា ជន ចូលចិត្តបំរើអ្នកអានដោយរូបភាពខ្មោចងាប់ នៅទំព័រមុខនឹងរឿងអាសអាភាសនៅទំព័រក្នុង តែក៏ជាកាសែតផ្តល់ពត៌មានលឿន ពេលខ្លះពី ព្រឹត្តិការគ្រោះថ្នាក់ធំៗ ដែលកើតមានក្នុងប្រ ទេស។ ផ្ទុយគ្នានេះ "កាសែតដំណឹងពេលព្រឹក" របស់លោក នួន នន់ ដែលឯករាជ្យតែជ្រេទៅ ខាងគណបក្សហ៊្វុនស៊ិនប៉ិច មានថ្វីដៃខាងសរ សេរនឹងដាក់ចំណងជើង គួរឱ្យចង់អានតែធ្វើ ការទស្សន៍ទាយនឹងឱ្យយោបល់ច្រើនដោយ មិនចាំបាច់ចេញទៅយកព័ត៌មាន ក៏បានដែរ... តែអ្នកអានចូលចិត្តជំនាញរបៀបនោះណាស់ ដែលធ្វើឱ្យកាសែតលក់ដាច់ច្រើនច្បាប់ ដោយ អានកំសាន្តច្រើនជាងអានព័ត៌មាន ដូច្នោះបើ មិនចាំបាច់មានការផ្សាយពាណិជ្ជកម្មច្រើនក៏រស់ បានដែរ ។

នៅមានកាសែតសេដ្ឋកិច្ច,កាសែតអារីយ ធម៌ កាសែត...ជាកាសែតធុនតូចរាប់សិបទៀត ដែលទទួលការទ្រទ្រង់ពីគណបក្សប្រជាជនចេញ ផ្សាយ១ពាន់ឬ២ពាន់ច្បាប់ ដែលរស់បានដោយ ការគាំទ្រសេដ្ឋកិច្ចពីគណបក្សប្រជាជន សម្រាប់ គេប្រើប្រាស់ជាសម្លេងឃោសនារបស់បក្ស។ ជាទូទៅអ្នកសរសេរច្រើនប្រើវិធីជម្រើតយកក ម្រៃពីប្រជាជនសម្រាប់រស់បន្ថែម ។

**នៅមានត**






# កម្មវិធីផ្តល់ជូនអាហារ សម្រាប់រដូវក្តៅ

## មិនគិតថ្លៃដល់កុមារ និងយុវជន

Merrimack Valley Food Bank, Inc.
Feeding Families Since 1991
Est. 1991

**ខែកក្កដា ទី 6 - សីហា ទី 14, 2020!!**

**ទូរស័ព្ទលេខៈ**
**1-800-645-8333**

**ផ្ញើសារ**
**"Food" រឺ "COMIDA" ផ្ញើទៅកាន់ 877-877**

**វ៉ិបសាយ**
**WWW.MEALS4KIDS.ORG**

**ដោនឡូតអាប់**
**"SUMMEREATS" សម្រាប់ IPHONE និង ANDROID**

កម្មវិធីផ្តល់ជូនអាហារសម្រាប់រដូវក្តៅមិនគិតថ្លៃដល់កុមារ និងយុវជនអាយុ 18 ឆ្នាំ និងមានអាយុក្រោមនេះៗ មិនត្រូវការចុះឈ្មោះ រឺ ចាំបាច់មាន I.D នោះទេៗ អង្គការនេះ គឺផ្តល់ឱកាសស្មើគ្នាៗ

ទីតាំងក្នុងការផ្តល់អាហារមានដូចខាងក្រោម!!

ផ្លូវ Caleb Group 77 Chestnut St.
(អាហារថ្ងៃត្រង់) 11:15 - 12:00
(អាហារសំរន់) 2:15-2:35 ថ្ងៃច័ន្ទ- សុក្រ

ផ្លូវ Eagle Park 95 W. 6th St.
(អាហារថ្ងៃត្រង់) 11:15-11:45 ថ្ងៃច័ន្ទ- សុក្រ

McPherson Pool 1000 Bridge St.
(អាហារថ្ងៃត្រង់) 12:15 -1:00 ថ្ងៃច័ន្ទ- សុក្រ

ផ្លូវ North Canal Apartments 517 Moody St.
(អាហារថ្ងៃត្រង់) 12:15 -12:45 ថ្ងៃអង្គារ-ព្រហស្បត្តិ៍

ផ្លូវ O'Donnell Splash Pad 1170 Gorham St.
(អាហារថ្ងៃត្រង់) 1:30 -2:00 Mon -Fri

PROJECT BREAD A FRESH APPROACH TO ENDING HUNGER
CNOP CHILD NUTRITION OUTREACH PROGRAM
MASSACHUSETTS DEPARTMENT OF ELEMENTARY AND SECONDARY EDUCATION